# **កាឡាទី ២:១-២១**

សូមអានកាឡាទី ២:១-២១ ទាំងមូល។

**ការរំលឹក:** នៅក្នុងកាឡាទី ១:១១-២៤ យើងបានរៀនថា ដំណឹងល្អដែលលោកប៉ុលបានថ្លែងប្រាប់នោះគាត់មិនបានទទួលមកពីមនុស្ស ក៏គ្មានអ្នកណាបង្រៀនគាត់ផងដែរ គឺដោយព្រះយេស៊ូវគ្រីស្ទបានបើកសំដែងវិញ។ លោកប៉ុលជាអ្នកដែលមានសិទ្ធិអំណាចមកពីព្រះអង្គធ្វើជាសាវក។ ជីវិតរបស់លោកប៉ុលបានសំដែងព្រះគុណដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ដែលព្រះអង្គបានសង្គ្រោះនិងប្រើលោកប៉ុលដែលពីមុនធ្លាប់ជាអ្នកបៀតបៀនគ្រីស្ទបរិស័ទ។

សូមអានខ.១-៥ ឡើងវិញហើយឆ្លើយសំនួរខាងក្រោម។

*តើ លោកប៉ុលបានថ្លែងប្រាប់ដំណឹងល្អនៅក្នុងពួកណា (ខ.២)?*

*តើ គេមិនបង្ខំឱ្យទីតុសធ្វើអ្វី (ខ.៣)?*

*តើ ពួកបងប្អូនក្លែងក្លាយបានធ្វើអ្វី (ខ.៤)?*

*ហេតុអ្វីបានជាលោកប៉ុលមិនព្រមចុះចូលនឹងពួកគេ (ខ.៥)?*

**ការពន្យល់ និងការអនុវត្ត** ការកាត់ស្បែកគឺជារឿងសំខាន់នៅក្នុងកណ្ឌកាឡាទី។ គ្រូក្លែងក្លាយបានបង្រៀនថា សាសន៍ដទៃដែលបានជឿលើព្រះគ្រីស្ទ ត្រូវកាត់ស្បែក។ នៅទីនេះលោកប៉ុលសរសេរថា សូម្បីតែគាត់បានទៅយេរូសាឡិមជាមួយទីតុសជាសាសន៍ក្រេក និងបានជួបពួកសាវកនៅទីនោះ ពួកសាវកមិនដែលបង្ខំឱ្យទីតុសកាត់ស្បែកទេ។ ប៉ុន្តែមានពួកយូដា (ពួកបងប្អូនក្លែងក្លាយ) ដែលបានស៊កសៀតចូលមក ដែលចង់នាំឱ្យគ្រីស្ទបរិស័ទជាប់ចំណងក្រិត្យវិន័យវិញ។ យើងត្រូវតាមគំរូរបស់លោកប៉ុល ហើយមិនត្រូវចុះចូលនឹងគ្រូក្លែងក្លាយឡើយ ដើម្បីអោយសេចក្តីពិតរបស់ដំណឹងល្អបាននៅស្ថិតស្ថេរ។

សូមអាន ខ.៦-១០ ឡើងវិញហើយឆ្លើយសំនួរខាងក្រោម។
*តើ លោកប៉ុលមានមុខងារផ្សព្វផ្សាយដំណឹងល្អដល់នរណា (ខ.៧-៨)?*

*តើ លោកពេត្រុសមានមុខងារផ្សព្វផ្សាយដំណឹងល្អដល់នរណា (ខ.៧-៩)?*

**ការពន្យល់:** «លោកបានលូកដៃស្តាំមកទទួលខ្ញុំ» មានន័យថាគេបានទទួលស្គាល់ថា លោកប៉ុលគឺជាសាវកពិតប្រាកដ ហើយបានទទួលដំណឹងល្អដែលគាត់បានប្រកាស។

*តើលោកយ៉ាកុប លោកកេផាស និងលោកយ៉ូហានសុំអោយលោកប៉ុលនិងគូកនរបស់គាត់ធ្វើអ្វី (ខ.១០)?*

**ការពន្យល់:** សញ្ញាចាស់បានបង្រៀនច្រើនអំពីការថែរក្សាអ្នកក្រីក្រ។ នៅសម័យរបស់លោកប៉ុលជនជាតិយូដាច្រើននៅយេរូសាឡិមមានសេចក្ដីទុក្ខលំបាក ហើយលោកប៉ុលបានប្រមូលតង្វាយពីពួកជំនុំផ្សេងៗដើម្បីអោយផ្គត់ផ្គង់អ្នកដែលខ្វះខាត (២កូរិនថូស ៨-៩)។

សូមអានខ. ១១-១៣។

*តើ ពេត្រុសបានធ្វើអ្វីខុស?*

**ការពន្យល់:** អាន់ទីយូកគឺជាក្រុងមួយនៅខាងជើងអ៊ីស្រាអែលហើយមានសាសន៍ដទៃច្រើន ដូច្នេះពួកជំនុំមានគ្រីស្ទបរិស័ទដែលមិនដែលកាត់ស្បែក។ ដោយព្រោះជនជាតិយូដាមានច្បាប់ខុសពីសាសន៍ដទៃអំពីបរិភោគអាហារ ពួកគេមិនធ្លាប់បរិភោគជាមួយគ្នាទេ។ កំហុសធំបំផុតរបស់ពេត្រុសគឺគាត់មិនកាន់កិរិយាមារយាទអោយបានសមរម្យនឹងដំណឹងល្អទេ ពីព្រោះតាមរយៈដំណឹងល្អនៃព្រះគ្រីស្ទ ព្រះអង្គបានប្រមូលសាសន៍ទាំងពីរ (យូដានិងសាសន៍ដទៃ) អោយរួមគ្នាមកជាប្រជារាស្ត្រតែមួយ។

សូមអានខ. ១៤។

*តើ លោកប៉ុលបានឆ្លើយយ៉ាងម៉េច?*

សូមអានខ. ១៥-១៦។

*តើ យើងអាចបានរាប់ជាសុចរិតដោយរបៀបណា? តើយើងបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រិត្យវិន័យឬ?*

*ហេតុអ្វីបានជាយើងមិនបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រិត្យវិន័យ?*

**ការពន្យល់:** នៅទីនេះលោកប៉ុលបង្រៀនថា ប្រសិនបើយើងជឿលើព្រះគ្រីស្ទ នោះយើងធ្វើបន្ទាល់ថា មនុស្សមិនបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រិត្យវិន័យទេ។ ដូច្នេះ ទស្សនៈដែលជឿថា មនុស្សអាចរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រិត្យវិន័យបាន នោះជាជំនឿមិនសមរម្យនឹងដំណឹងល្អទេ។

*តើ អ្នកធ្លាប់ (ឬស្គាល់អ្នកណាធ្លាប់) ស្វែងរកសេចក្ដីសង្គ្រោះតាមរយៈការប្រព្រឹត្តរបស់ខ្លួនដែរទេ?*

សូមអានខ. ១៧-២០។

*កាលយើងខ្ញុំកំពុងតែស្វែងរកឱ្យបានរាប់ជាសុចរិតក្នុងព្រះគ្រីស្ទ តើព្រះគ្រីស្ទជាអ្នកចែកចាយអំពើបាបឬអី?*

**ការពន្យល់ និងការអនុវត្ត** មនុស្សច្រើនជឿថា បើសិនជាយើងបង្រៀនថា ព្រះជាម្ចាស់រាប់យើងជាសុចរិតដោយជំនឿ នោះនឹងលើកទឹកចិត្តមនុស្សប្រព្រឹត្តអំពើបាប ដូច្នេះព្រះគ្រីស្ទចែកចាយអំពើបាប។ លោកប៉ុលបដិសេធ

គំនិតនេះ ប៉ុន្តែគាត់មិនបង្រៀនថា យើងត្រូវទៅក្រិត្យវិន័យវិញទេ។ ផ្ទុយទៅវិញ «ខ្ញុំបានស្លាប់ខាងឯក្រិត្យវិន័យ» (ខ.១៩)។ យើងមិនជាមនុស្សជាប់បាបទេ ពីព្រោះ «ព្រះគ្រីស្ទទេតើ ដែលមានព្រះជន្មរស់នៅក្នុងរូបកាយខ្ញុំ» ហើយ «ខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿជឿដល់ព្រះរាជបុត្រានៃព្រះ»។ នេះជាគោលការណ៍ដ៏សំខាន់នៅក្នុងជីវិតរបស់គ្រីស្ទបរិស័ទ។ អ្នកដឹកនាំនៅក្នុងពួកជំនុំត្រូវប្រកាសជីវិតនៅក្នុងព្រះគ្រីស្ទ មិនមែនប្រកាសថា មនុស្សអាចសង្គ្រោះបានដោយប្រព្រឹត្តតាមក្រិត្យវិន័យឡើយ។ យើងមិនអាចមានជីវិតបរិសុទ្ធដោយសារក្រិត្យវិន័យបាននោះទេ ប៉ុន្តែដោយព្រះគ្រីស្ទមានព្រះជន្មរស់នៅក្នុងយើង។

សូមអាន ខ.២១។

បើសិនជាសេចក្តីសុចរិតមកដោយសារក្រិត្យវិន័យនោះ________________________________________។

ដូច្នេះ ការបង្រៀនថា មនុស្សអាចសេចក្តីសុចរិតមកដោយសារយើងប្រព្រឹត្តតាមក្រិត្យវិន័យ គឺជារឿងធ្ងន់ណាស់។

**ការអនុវត្ត:** នៅជំពូក២ លោកប៉ុលបានបង្រៀនសេចក្តីពិតខដ៏សំខាន់សំរាប់គ្រីស្ទបរិស័ទ។ យើងត្រូវតាមគំរូរបស់លោកប៉ុល ដោយការពារសេចក្តីពិតរបស់ដំណឹងល្អ ដើម្បីអោយសេចក្តីពិតនោះបាននៅស្ថិតស្ថេរ។ សេចក្តីពិតរបស់ដំណឹងល្អប្រកាសថា មនុស្សមិនបានសង្គ្រោះឬរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រិត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ (ខ.១៦)។ លោកប៉ុលបានបង្រៀនអំពីខ្លឹមសារនៃជីវិតរបស់គ្រីស្ទបរិស័ទ ខ្លឹមសារនោះគឺ «ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅមិនមែនជាខ្ញុំទៀតគឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះនោះ គឺរស់ដោយសេចក្តីជំនឿជឿដល់ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ»(ខ.២០)។

**រំលឹកឡើងវិញ** *តើយើងបានរៀនអ្វីចេញពីកាឡាទី ២:១-២១?*